**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

សុន្ទរកថា

ឯកឧត្តមទេសរដ្ឋមន្ត្រី **អៀង មូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

និង ជាប្រធានគណៈកម្មាធិការសម្របសម្រួលប្រចាំប្រទេសកម្ពុជា

ក្នុងពិធីបើកកិច្ចប្រជុំពិគ្រោះយោបល់ស្តីពីការពង្រឹងប្រព័ន្ធសុខាភិបាល ៖

កិច្ចសន្ទនាប្រចាំប្រទេសឆ្នាំ២០១៥

សណ្ឋាគារ ណាហ្គាវើល ថ្ងៃពុធ ទី១៤ ខែមករា ឆ្នាំ២០១៤

សូមគោរព ៖

- *ឯកឧត្តម លោកជំទាវ ជាគណៈអធិបតី*
- *លោកជំទាវសាស្ត្រាចារ្យ គ្រុយ លាងស៊ីម អនុរដ្ឋលេខាធិការ ក្រសួងសុខាភិបាល*
- *លោកជំទាវ ឱ វណ្ណឌីន អគ្គនាយកបច្ចេកទេស ក្រសួងសុខាភិបាល*
- *ឯកឧត្តម អនុប្រធាន ទីប្រឹក្សា អគ្គលេខាធិការ អគ្គលេខាធិការរង អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍*
- *ឯកឧត្តម លោកជំទាវ  លោក លោកស្រី តំណាងស្ថាប័នរាជរដ្ឋាភិបាល អង្គទូត ដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល*
- *លោក លោកស្រី ជាទីប្រឹក្សាបច្ចេកទេស និង អ្នកជំនាញការទាំងអស់*

ជាបឋម ខ្ញុំសូមសម្តែងនូវសេចក្តីសោមនស្សរីករាយដែលត្រូវបានអញ្ជើញជាអធិបតីមកបើកកិច្ចប្រជុំពិគ្រោះយោបល់ស្តីពី  ការពង្រឹងប្រព័ន្ធសុខាភិបាល ៖ កិច្ចសន្ទនាប្រចាំប្រទេសឆ្នាំ២០១៥ នាថ្ងៃនេះ ។ ខ្ញុំក៏សូមសម្តែងនូវការស្វាគមន៍យ៉ាងកក់ក្តៅ និង ថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះ ឯកឧត្តម  លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញា  ដែលអញ្ជើញមកពីគ្រប់ទិសទី ដើម្បីចែករំលែកនូវគំនិតក្នុងការពិនិត្យ  មើល និងផ្តល់ការគាំទ្រលើកំណាត់បង្ហាញ

ទស្សនៈក្នុងការពង្រឹងប្រព័ន្ធសុខាភិបាល ដែលរួមចំណែកយ៉ាងសកម្មដល់គោលដៅអភិវឌ្ឍសហស្សវត្សរ៍ ថ្នាក់ជាតិដែលជាប់ពាក់ព័ន្ធនឹងវិស័យសុខាភិបាល និង ចូលរួមក្នុងចលនាសកលលោក ដើម្បីធ្វើឱ្យពិភពលោករួចចាកផុតពីជំងឺអេដស៍ របេង និង គ្រុនចាញ់ ។

ខ្ញុំសូមរំឭកថា ក្នុងខែមិថុនា ឆ្នាំ២០១៤ មូលនិធិសកលបានប្រកាសថា ផ្តល់កញ្ចប់ថវិកាដល់កម្ពុជាចំនួន ១៤៨,៨ លានដុល្លារអាម៉េរិកដើម្បីប្រយុទ្ធនឹងជំងឺឆ្លង ៣ គឺ ជំងឺគ្រុនចាញ់ អេដស៍ និង របេង ព្រមទាំងការពង្រឹងប្រព័ន្ធសុខាភិបាល ។ ការផ្តល់កញ្ចប់ថវិកា ១៦,៣ លានដុល្លារអាម៉េរិក ឬស្មើនឹង ៦% នៃថវិកាទាំងមូលត្រូវបានសម្រេចផ្តល់ឱ្យវិស័យអាទិភាពជាគន្លឹះនៃផែនការយុទ្ធសាស្ត្រសុខាភិបាល ២០០៨-២០១៥ ។ ថ្ងៃនេះ ដោយទទួលបានបទពិសោធន៍ពីកម្មវិធីជំងឺរបេង គ្រុនចាញ់ និង អេដស៍ យើងកំពុងប្រើវេទិកាពិសេសនេះដើម្បីផ្លាស់ប្តូរ និង ច្របាច់បញ្ចូលទស្សនៈរបស់យើង ដើម្បីរួមគ្នាគាំទ្រចំពោះអាទិភាពជាគន្លឹះនៃកំណត់បង្ហាញទស្សនៈ ហើយកាន់តែសំខាន់ជាងនោះគឺគាំទ្រការវិនិយោគចំពោះអន្តរាគមន៍នានាជាគន្លឹះក្នុងការឆ្លើយតបវិស័យជាអាទិភាពគន្លឹះទាំងនោះ ។ យើងនឹងធ្វើការសម្រេចរួមគ្នាផងដែរថាតើកម្មវិធីនេះនឹងត្រូវបានគ្រប់គ្រង ដែលអាចឱ្យយើងចូលទៅកៀកអ្នកដែលទទួលផលប៉ះពាល់ពីជំងឺប្រកបដោយប្រសិទ្ធភាព និង ទទួលបានលទ្ធផលអតិបរមាទៅតាមតម្រូវការរបស់សហគមន៍ ។

សូមអនុញ្ញាតឱ្យខ្ញុំរំឭកពីស្ថានភាពកាលពីមួយទសវត្សមុន ។ កាលពី១០ឆ្នាំមុន យើងទាំងអស់គ្នាបានដាក់ចេញនូវទិសដៅចំពោះវិស័យដែលទទួលខុសត្រូវរៀងៗខ្លួន ។ យើងទាំងអស់គ្នាបានដាក់សំណើសុំថវិកាទៅមូលនិធិសកលចំនួនជាង ៤០០លានដុល្លារដោយជោគជ័យក្នុងការគាំទ្រដល់ការបំពេញកិច្ចការងារនានាដែលមាននៅក្នុងសំណើសុំជាជុំ។ ចេញពីកិច្ចប្រឹងប្រែងរួមរបស់យើងទាំងអស់គ្នា អត្រាប្រេវ៉ាឡង់មេរោគអេដស៍នៅក្នុងចំណោមប្រជាជនទូទៅនៅកម្ពុជា ត្រូវបានធ្លាក់ចុះមកនៅ ០,៦% នៅឆ្នាំ២០១៥ អត្រាប្រេវ៉ាឡង់ជំងឺរបេងសួតបានធ្លាក់ចុះពី៣៨% ឬ ៤,២%ប្រចាំឆ្នាំ នៅចន្លោះឆ្នាំ ២០០២ ដល់ឆ្នាំ២០១១ ខណៈដែលករណីជំងឺគ្រុនចាញ់ត្រូវបានកាត់បន្ថយប្រមាណពាក់កណ្តាលនៅចន្លោះឆ្នាំ២០០០ និង ២០១០ ។ បន្ទាប់មក យើងទាំងអស់គ្នាអាចអះអាងថា ចេញពីកិច្ចប្រឹងប្រែងនានាកាលពី១០ឆ្នាំមុន យើងពិតជាសម្រេចបានគោលដៅអភិវឌ្ឍសហស្សវត្សរ៍ពាក់ព័ន្ធនឹងសុខាភិបាលមុនឆ្នាំ២០១៥ ។ គោលដៅទាំងនោះរួមមានការកាត់បន្ថយអត្រាមរណភាពមាតា អត្រាមរណភាពកុមារ អត្រាមរណភាពដោយជំងឺរបេង និង គ្រុនចាញ់ ។

យើងទាំងអស់គ្នាមានមោទនភាពចំពោះសមិទ្ធផលទាំងនោះ ។

*ឯកឧត្តម លោកជំទាវ លោក លោកស្រី!*

ឥឡូវនេះយើងមានអាយុចាស់ជាងមុន ១០ឆ្នាំ តើយើងទាំងអស់គ្នាកំពុងតែរំភើបសប្បាយជាមួយនឹងទស្សនៈនៃគំរូហិរញ្ញប្បទានថ្មី ឬទេ?

ដើម្បីជួយឱ្យអ្នកទាំងអស់គ្នាជ្រើសរើសនូវចម្លើយ សូមអនុញ្ញាតឱ្យខ្ញុំជម្រាបជូននូវភាសិតដែលល្បីល្បាញមួយថា "ជោគជ័យបង្កើតបានជាការពេញចិត្ត ។ ការពេញចិត្តបង្កើតបានជាការបរាជ័យ ។ មានតែអ្នកដែលមានការបារម្ភសង្ស័យទេដែលនៅរស់រានមានជីវិត" ។

ដូច្នេះ ដើម្បីឆ្លើយនឹងសំណួរខាងលើ យើងមិនអាចដកខ្លួនយើងចេញពីអន្ទាក់បានឡើយ ។ យើងមិនអាចស្ថិតក្នុងអារម្មណ៍ដែលពេញចិត្ត យើងគួរមានសេចក្តីរំភើបសប្បាយ និង បារម្ភសង្ស័យ ពីព្រោះយើងមិនចង់បរាជ័យ និង ចង់រស់រានមានជីវិត ។ ហេដ្ឋារចនាសម្ព័ន្ធសុខាភិបាលរបស់យើងត្រូវការនូវការគាំទ្រ ដើម្បីផ្តល់នូវសេវាសុខភាពមួយដែលមានគុណភាពដល់ប្រជាជនកម្ពុជាទាំងអស់ដែលរស់នៅពាសពេញផ្ទៃប្រទេស ។

នៅក្នុងរយៈពេលជាងបួនខែកន្លងទៅនេះ (តាំងពីថ្ងៃទី១ ខែកញ្ញា) គណៈកម្មាធិការដឹកនាំត្រូវបានប្រគល់ភារកិច្ចឱ្យធ្វើជាយន្តការដឹកនាំប្រចាំប្រទេស រៀបចំការប្រជុំចំនួន ១២ដង ហើយ បានឈានដល់ការសម្រេចចិត្តមួយ ក្នុងការរៀបចំផែនការដែលគ្របដណ្តប់លើវិស័យប្រធានបទ៤ ៖

១) បង្កើនប្រសិទ្ធភាព និង ប្រសិទ្ធផលចំពោះកិច្ចអន្តរាគមន៍លើ ជំងឺរបេង គ្រុនចាញ់ មេរោគអេដស៍/ជំងឺអេដស៍ ដោយរកឱ្យឃើញនូវឱកាសនានាក្នុងការធ្វើសមាហរណកម្ម និង កែលម្អប្រសិទ្ធភាពដែលប្រកបដោយសក្តានុពលដែលទទួលបានក្នុងចំណោម ជំងឺទាំងនោះ និង នៅពាសពេញប្រព័ន្ធសុខាភិបាល

២) បង្កើននូវតម្រូវការសេវាសុខាភិបាល នៅកម្រិតសហគមន៍តាមរយៈការគាំទ្រប្រព័ន្ធសហគមន៍ដ៏រឹងមាំមួយដែលជំរុញឱ្យមានការចូលរួមពីសហគមន៍ក្នុងវិស័យសុខាភិបាល

៣) កាត់បន្ថយមរណភាពមាតា និង ទារកទើបនឹងកើត ដោយការបង្កើន និង ការកែលម្អនូវការទទួលយកសេវាថែទាំស្ត្រីមានគភ៌ ការសម្រាល និង ទារកទើបនឹងកើត និង

៤) កែលម្អការផ្គត់ផ្គង់ឈាមដែលអាចរកបាន និង មានគុណភាព ។

មុននឹងយើងចូលកាន់តែជ្រៅក្នុងការពិភាក្សាលម្អិតស្តីពីវិស័យប្រធានបទនានា សូមអនុញ្ញាតឱ្យខ្ញុំឆ្លៀតឱកាសនេះធ្វើបច្ចុប្បន្នភាពបរិបទសំខាន់ ៣ ដែលអាចជះឥទ្ធិពលដល់ការរៀបចំវិស័យអាទិភាពនៃកំណត់បង្ហាញទស្សនៈស្តីពីការពង្រឹងប្រព័ន្ធសុខាភិបាលរបស់យើង ។

១)	ដើម្បីធ្វើការអនុវត្តប្រកបដោយជោគជ័យក្នុងគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល ដែលបានដាក់ចេញនៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ សម្រាប់នីតិកាលទី៥នៃរដ្ឋសភា សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានទទូចសុំឱ្យរាល់ភ្នាក់ងាររដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ វិស័យឯកជន ស្ថាប័នសង្គមស៊ីវិល និង អ្នកពាក់ព័ន្ធផ្សេងទៀតប្រកាន់ខ្ជាប់យ៉ាងតឹងរ៉ឹងនូវអាទិភាពនានាដែលបានដាក់ចេញដោយ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០១៤-២០១៨ ដែលជាផែនទីបង្ហាញផ្លូវសម្រាប់ការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ ។

២) មានការកើនឡើងជាលំដាប់នូវថវិកាជាតិគាំទ្រវិស័យសុខាភិបាល ក្នុងពេលដែលការគាំទ្រពីដៃគូអភិវឌ្ឍន៍កំពុងថយចុះ ។ ក្នុងន័យនេះ ក្នុងឋានៈជាប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ខ្ញុំសូមជម្រាបជូនអ្នកទាំងគ្នាដែលមានវត្តមាននៅទីនេះថា រាជរដ្ឋាភិបាលនឹងរួមចំណែកជាមួយមូលនិធិសកលក្នុងការផ្តល់ថវិកាជាតិ ដើម្បីទិញឱសថប្រឆាំងនឹងមេរោគអេដស៍ ចំនួន ១លានដុល្លារនៅឆ្នាំ២០១៥ ១,២លានដុល្លារនៅឆ្នាំ២០១៦ និង ១,៥លានដុល្លារនៅឆ្នាំ២០១៧ ។

៣) ចំពោះវិស័យសុខាភិបាល ក្រសួងសុខាភិបាលឈានទៅស្ថាបនា និង ពង្រឹងប្រព័ន្ធខ្លួនផ្ទាល់ ដើម្បីសម្រេចបាននូវគោលដៅសហស្សវត្សរ៍ដែលជាប់ពាក់ព័ន្ធនឹងសុខាភិបាល និង សំខាន់បំផុតគឺការរៀបចំប្រព័ន្ធប្រចាំប្រទេសផ្ទាល់ ចំពោះគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ក្រោយឆ្នាំ២០១៥ ។ នៅក្នុងដំណាក់កាលអន្តរកាលដ៏សំខាន់នេះ យើងកំពុងស្ថិតនៅក្នុងបរិយាកាសមួយដែលមិនអាចដឹងមុន ដែលថវិកាមូលនិធិសកល និង ម្ចាស់ជំនួយផ្សេងទៀតកំពុងថយចុះ ហើយកម្មវិធីមេរោគអេដស៍ របេង និង គ្រុនចាញ់ កាន់តែមានភាពជឿនលឿន និង តម្រូវឱ្យមានការកំណត់ទិសដៅ ។ ក្នុងពេលវេលាដ៏ពិសេសនេះ កម្ពុជាត្រូវតែមានលក្ខណៈបុរេសកម្ម ក្នុងការរៀបចំផែនការហិរញ្ញវត្ថុដែលមានចីរភាពរបស់ខ្លួននៅក្នុងកម្មវិធីទាំងនេះ ។ ក្រៅពីនេះ មានការប្រញាប់បន្ទាន់ក្នុងការពង្រឹងប្រព័ន្ធសុខាភិបាលទាំងមូល និង ការផ្ទេរដំណាក់កាលទៅកាន់សេវាសុខភាពដែលកាន់តែត្រូវរួមបញ្ចូលគ្នា និង មានភាពសុខដុមដើម្បីគាំទ្រជំងឺទាំង៣ ។

*ឯកឧត្តម លោកជំទាវ លោក លោកស្រី!*

ថ្ងៃនេះ សេចក្តីព្រាងសំណើសុំថវិកាចំនួន ១២,៣លានដុល្លារ ត្រូវបានដាក់ជូនអ្នកពាក់ព័ន្ធទាំងអស់ក្នុងវេទិកាកិច្ចសន្ទនាប្រចាំប្រទេសនាពេលនេះ ដើម្បីពិនិត្យមើល និង ផ្តល់ការ

គាំទ្រមុននឹងផ្ញើជូនទៅមូលនិធិសកល តាមរយៈយន្តការសម្របសម្រួលប្រចាំប្រទេសឱ្យបានមុនដំណាច់ខែមករា ឆ្នាំ២០១៥ ។ អស់លោកអ្នកអាចនឹងស្មានដឹងជាមុនថា នឹងមានការសួរនាំ និង ការប្រាស្រ័យទាក់ទងរវាងប្រទេស និង គណៈកម្មាការវាយតម្លៃបច្ចេកទេស (Technical Review Panel) និង គណៈកម្មាធិការអនុម័តថវិកាជំនួយ (Grant Approval Committee) ដើម្បីឈានទៅដល់ការសម្រេចចុងក្រោយលើសំណើសុំ និង ចាប់ផ្តើមផ្តល់នូវថវិកាជំនួយដល់ការពង្រឹងប្រព័ន្ធសុខាភិបាល ។

ជាមួយគ្នានេះ ខ្ញុំសូមអំពាវនាវដល់អ្នកតំណាងនានាពី ប្រជាជនរងផលប៉ះពាល់ទាំងអស់ អ្នកផ្ទុកមេរោគ ស្ថាប័នដែលពឹងផ្អែកលើអង្គការ សង្គមស៊ីវិល ឱ្យចូលរួមយ៉ាងសកម្មក្នុងការពិភាក្សាជាក្រុម ឬពេញអង្គ ជាមួយអ្នកបម្រើសេវាថែទាំសុខភាព ស្ថាប័នឧត្តមសិក្សា អ្នកស្រាវជ្រាវ និង មន្ត្រីសាធារណៈផ្សេងទៀត ក្នុងការអង្កេតលើវិស័យប្រធានបទដូចខាងក្រោម ៖

១) ការផ្គត់ផ្គង់ឱសថ និង ការប្រើប្រាស់ប្រកបដោយវិចារណញ្ញាណ

២) ប្រព័ន្ធព័ត៌មានសុខាភិបាល

៣) ក្រុមការងារសុខភាពសហគមន៍

៤) អភិបាលកិច្ច

៥) ការផ្តល់សេវា

- មុនពេលសម្រាល/ការកាត់បន្ថយការចម្លងពីម្តាយទៅកូន
- ការបង្ការ និង ការគ្រប់គ្រងជំងឺឆ្លង
- សុវត្ថិភាពឈាម
- ការពង្រឹងគុណភាពការព្យាបាលវេជ្ជសាស្ត្រនៅក្នុងវិស័យឯកជន

ខ្ញុំមានជំនឿលើឯកឧត្តម លោកជំទាវ អស់លោក លោកស្រីទាំងអស់ថានឹងរំឭកគ្នាជាប្រចាំ ដើម្បីធ្វើឱ្យកំណត់បង្ហាញទស្សនៈនេះ មានភាពសុខដុម និង រួបរួមគ្នា ស្របនឹងកម្មវិធីមេរោគអេដស៍ និង ជំងឺអេដស៍ របេង និង គ្រុនចាញ់ និង សំខាន់បំផុតគឺ ធ្វើឱ្យស៊ីសង្វាក់គ្នាជាមួយគោលការណ៍ណែនាំជាយុទ្ធសាស្ត្ររបស់ក្រសួងសុខាភិបាល នាពេលបច្ចុប្បន្ន ។

*ឯកឧត្តម លោកជំទាវ លោក លោកស្រី!*

សូមអនុញ្ញាតឱ្យខ្ញុំជម្រាបជូនពីបញ្ហាសំខាន់ផ្សេងទៀត ដើម្បីជាការត្រិះរិះពិចារណា ៖ "ចំណុចសំខាន់របស់យើងចាប់ផ្តើមពីអ្នកជួរមុខរបស់យើង"។ តើវាមានន័យយ៉ាងណា?

អត្ថន័យនោះគឺថា យើងមិនអាចទទួលបានជោគជ័យក្នុងការពង្រឹងប្រព័ន្ធសុខាភិបាល ដោយគ្មានការគាំទ្រពីអ្នកធ្វើកិច្ចការជួរមុខដូចជា អ្នកស្ម័គ្រចិត្តតាមប្រភេទជំងឺ និង ក្រុមគាំទ្រសុខភាពភូមិបានឡើយ ។ ដូច្នេះត្រូវធានាថានៅស្រទាប់ក្រោមថ្នាក់មូលដ្ឋានបានទទួលនូវការគាំទ្រដ៏សមស្រប ។

១) យើងត្រូវធានាថាយើងមានប្រភពធនធានសម្រាប់កម្រិតវិមជ្ឈការ

២) យើងត្រូវធានាថាបណ្តាញនៅស្រទាប់ក្រោមថ្នាក់មូលដ្ឋានមានដំណើរការ។

ចំពោះប្រភពធនធាននៅស្រទាប់ក្រោមថ្នាក់មូលដ្ឋាន ខ្ញុំសូមជម្រាបជូនថា កិច្ចប្រឹងប្រែងនៅក្នុង វិមជ្ឈការ និង វិសហមជ្ឈការ នៃរាជរដ្ឋាភិបាលកម្ពុជា មូលនិធិសម្រាប់បញ្ហាសង្គមដូចជា សុខភាព និង អនាម័យ មាតា និង ទារក ត្រូវបានដាក់ទៅដល់កម្រិតឃុំតាមរយៈផែនការវិនិយោគឃុំ ។ ស្របជាមួយនឹងវិធី សាស្ត្រដែលមានការច្នៃប្រឌិតនេះជាមួយនឹងការរៀបចំ កំណត់បង្ហាញទស្សនៈអំពីមេរោគអេដស៍ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍មានផែនការដាក់បញ្ចូលមេរោគអេដស៍/ជំងឺអេដស៍ ក្នុងផែនការអភិវឌ្ឍឃុំ/ផែនការវិនិយោគឃុំ ដែលមានចំនួន ១៦២១ឃុំនៅទូទាំងប្រទេស ដោយការផ្តល់ថវិកាជាយុទ្ធសាស្ត្រមួយចំនួនដល់គ្រួសារដែលត្រូវការបំផុត ។

ដើម្បីធានាថា បណ្តាញស្រទាប់ក្រោមបំផុតមានដំណើរការ ខ្ញុំសូមស្នើអ្នកចូលរួមទាំងអស់រៀបចំឱ្យបាននូវលក្ខណៈច្នៃប្រឌិត ដែលការព្យាបាលក្រោមការត្រួតពិនិត្យដោយផ្ទាល់ផ្អែកលើសហគមន៍នៃកម្មវិធីជំងឺរបេង អ្នកស្ម័គ្រចិត្តគាំទ្រសហគមន៍នៃកម្មវិធីអេដស៍ និង អ្នកធ្វើការជំងឺគ្រុនចាញ់ភូមិនៃកម្មវិធីជំងឺគ្រុនចាញ់ អាចធ្វើឱ្យមានសុខដុមជាមួយអ្នកស្ម័គ្រចិត្តសុខាភិបាលភូមិ នៅមូលដ្ឋាន។ម្យ៉ាងទៀត យើងត្រូវធានាថាអ្នកស្ម័គ្រចិត្តទាំងនោះធ្វើការងារជាមួយអ្នកធ្វើការថែទាំសុខភាពនៅមណ្ឌលសុខភាព និង ជាមួយជនបង្គោលស្ត្រី និង កុមារនៅតាមឃុំ ។

ខ្ញុំមានជំនឿថា កិច្ចប្រឹងប្រែងរួមរបស់យើងក្នុងរៀបចំកំណត់បង្ហាញទស្សនៈនាថ្ងៃនេះក្នុងការពង្រឹងប្រព័ន្ធសុខាភិបាលនឹងរួមចំណែកយ៉ាងធំធេងដល់ ការលើកកម្ពស់ស្រទាប់ដែលក្រីក្របំផុតក្នុងសង្គមពីលក្ខខណ្ឌសុខាភិបាលដែលខ្សត់ខ្សោយ ព្រមទាំងជួយពួកគេឱ្យតាមទាន់ក្រុមផ្សេងទៀតដែលទទួលបានអត្ថប្រយោជន៍ពីកំណើនសេដ្ឋកិច្ច ក្នុងពេលដែលកែលម្អនូវផលិតភាពផ្ទាល់របស់ពួកគេ និង ការទទួលបានការងារកាន់តែល្អប្រសើរ ។

ខ្ញុំសូមសម្តែងនូវការស្វាគមន៍ចំពោះ ការរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ដ៏សំខាន់នេះ និង សូមជូនពរឱ្យមានការពិភាក្សាផុលផុស និង រៀបចំនូវកំណត់បង្ហាញទស្សនៈពេញលេញដោយជោគជ័យ ដែលអាចអនុវត្តបានប្រកបដោយប្រសិទ្ធភាព ។

ខ្ញុំសូមប្រសិទ្ធពរជូន ឯកឧត្តម លោកជំទាវ លោក  លោកស្រី និង អ្នកចូលរួម ទាំងអស់នូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និង ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

ខ្ញុំសូមប្រកាសបើក កិច្ចប្រជុំពិគ្រោះយោបល់ស្តីពីការពង្រឹងប្រព័ន្ធសុខាភិបាល ៖ កិច្ចសន្ទនាប្រចាំប្រទេសឆ្នាំ២០១៥ ការពិនិត្យមើល និង ការផ្តល់ការគាំទ្រសេចក្តីព្រាងកំណត់បង្ហាញទស្សនៈក្នុងការពង្រឹងប្រព័ន្ធសុខាភិបាល ចាប់ពីពេលនេះតទៅ ។

*សូមអរគុណ!*